24 កុម្ភៈ 2017



**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ៦២០៨.....សហវ.ប្រក

# ប្រកាស
## ស្តីពី
## ការបង្កើតរជ្ជទេយ្យបុរេប្រទានសម្រាប់ឆ្នាំ២០១៧
## របស់អគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ

## ទេសរដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើប្រាស់ច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៦/០១៩ ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៧
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៨១ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុលើការចំណាយថវិការដ្ឋនៅតាមក្រសួង ខេត្ត ក្រុង ក្រុងស្វយ័ត រាជធានីភ្នំពេញ និង អង្គការសាធារណៈរដ្ឋបាល
- បានឃើញប្រកាសលេខ ០០៤ សហវ.ម.ប្រក ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការអនុវត្តបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ

- បានឃើញប្រកាសលេខ១៨៩ សហវ.ប្រក ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៣ ស្តីពីការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ច នៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញប្រកាសលេខ ២១១ សហវ.ប្រក ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១៣ ស្តីពីការដាក់ឱ្យអនុវត្តមាតិកាគណនី នៃប្លង់គណនេយ្យថវិការបស់រដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- បានឃើញប្រកាសលេខ ១៣៣ សហវ.ប្រក ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៥ ស្តីពីការបង្កើតនិងដាក់ឱ្យដំណើរការអង្គភាពថវិការបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ ១៩៣៧ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ ២០១៤ ស្តីពីនីតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទានសម្រាប់រដ្ឋបាលថ្នាក់ជាតិ
- បានឃើញប្រកាសលេខ ៨២៩ សហវ.ប្រក ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលប្រការ៤ ប្រការ៥ ប្រការ១៤ ប្រការ១៦ និងប្រការ១៧ នៃប្រកាសលេខ ១៩៣៧ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីនីតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទានសម្រាប់រដ្ឋបាលថ្នាក់ជាតិ
- បានឃើញប្រកាសលេខ ១៨៤១ សហវ.ប្រក ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៥ ស្តីពីការប្រគល់សិទ្ធិជាអាណាប័កផ្ទេរសិទ្ធិលើឥណទានថវិការជ្ជទេយ្យបុរេប្រទាន ជូនប្រធានអង្គភាពថវិកា នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ ២៨០ សហវ.ប្រក ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១៥ ស្តីពីការតែងតាំងរជ្ជទេយ្យករបុរេប្រទាន និងរជ្ជទេយ្យករបុរេប្រទានរងរបស់អង្គភាពថវិកានៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញសារាចរណែនាំលេខ ០០៤ សហវ ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៦ ស្តីពី ការបង្កើតតារាងឧបសម្ព័ន្ធរជ្ជទេយ្យបុរេប្រទានសម្រាប់ថវិកាកម្មវិធី
- បានឃើញសេចក្តីណែនាំលេខ ០០៤ សហវ ចុះថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០១៦ ស្តីពីវិធាន និងនីតិវិធី នៃការរៀបចំ និងការអនុវត្តចំណាយតាមរជ្ជទេយ្យបុរេប្រទានសម្រាប់ដំណើរការផ្ទៃក្នុងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញសេចក្តីណែនាំលេខ ០០៥ សហវ ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០១៥ ស្តីពីគោលការណ៍និងនីតិវិធីផ្ទៃក្នុងសម្រាប់ការអនុវត្តថវិកាកម្មវិធី របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- យោងតាមតម្រូវការចាំបាច់នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ១.-**

ត្រូវបានបង្កើតរជ្ជទេយ្យបុរេប្រទានថវិកាជំពូក៦០ “ការទិញ” និងជំពូក៦១ “សេវាកម្ម” នៅអគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ សម្រាប់មុខសញ្ញាចំណាយ ដូចមានចែងក្នុងប្រការ៥ថ្មី នៃប្រកាសលេខ ៨២៩ សហវ.ប្រក ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលប្រការ៤ ប្រការ៥ ប្រការ១៤ ប្រការ១៦ និងប្រការ១៧ នៃប្រកាសលេខ១៩៣៧សហវ.ប្រកចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីនីតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទានសម្រាប់រដ្ឋបាលថ្នាក់ជាតិ។

តារាងឧបសម្ព័ន្ធរជ្ជទេយ្យបុរេប្រទាន ត្រូវបានកំណត់ជាឧបសម្ព័ន្ធ នៃប្រកាសនេះ។

**ប្រការ២.-**

ចំនួនទឹកប្រាក់មួយជុំបង្វិល នៃរជ្ជទេយ្យបុរេប្រទាន ត្រូវកំណត់ដូចក្នុងតារាងឧបសម្ព័ន្ធរជ្ជទេយ្យបុរេប្រទាន។

**ប្រការ៣.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៤.-**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ អគ្គនាយកនៃអគ្គនាយកដ្ឋានរតនាគារជាតិ អគ្គនាយកនៃអគ្គនាយកដ្ឋានថវិកា អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន នាយកវិទ្យាស្ថាន ប្រធានគ្រប់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី[illegible] ខែ[illegible] ឆ្នាំ២០១៧

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល÷**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមុខងារសាធារណៈ
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- សាមីអង្គភាពថវិកា
- ដូចប្រការ៤
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
អគ្គនាយកដ្ឋានអគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ

## តារាងរចនាសម្ព័ន្ធរដ្ឋទេយ្យបុរេប្រទានចំពោះការទូទាត់តាមចំណាត់ថ្នាក់សេដ្ឋកិច្ចឆ្នាំ២០១៧
## របស់អគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ

ឯកតា÷រៀល

| ជំពូក | គណនី | អនុគណនី | បរិយាយ | ច្បាប់ហិរញ្ញវត្ថុ ឆ្នាំ ២០១៧ | ឥណទាន ដែលជ្រើសរើស | ឥណទាន រដ្ឋទេយ្យបុរេប្រទាន | ឥណទាន ទូទាត់ត្រង់ | ឥណទាន១ជុំបង្វិល រដ្ឋទេយ្យបុរេប្រទាន | ភាគរយ |
|---|---|---|---|---|---|---|---|---|---|
| | | | | ១ | ២ | ៣ | ៤=២-៣ | ៥=៣/៤ជុំ | ៦=៣/២ |
| | | | សរុបរួម | 1,506,000,000.0 | 1,409,900,000.0 | 854,100,000.0 | 555,800,000.0 | 213,525,000.0 | 112.65% |
| 60 | | | ការទិញ | 651,000,000.0 | 621,000,000.0 | 127,900,000.0 | 493,100,000.0 | 31,975,000.0 | 20.60% |
| | 6001 | | សម្ភារៈផ្គត់ផ្គង់ថែទាំ | 30,800,000.0 | 800,000.0 | 800,000.0 | 0.0 | 200,000.0 | 100.00% |
| | | 60011 | សម្ភារៈផ្គត់ផ្គង់សម្អាតនិងអនាម័យ | 800,000.0 | 800,000.0 | 800,000.0 | 0.0 | 200,000.0 | 100.00% |
| | | 60015 | ប្រេងឥន្ធនៈនិងប្រេងរំអិល | 30,000,000.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | 6002 | | សម្ភារៈផ្គត់ផ្គង់ផ្នែករដ្ឋបាល | 503,100,000.0 | 503,100,000.0 | 115,100,000.0 | 388,000,000.0 | 28,775,000.0 | 22.88% |
| | | 60021 | សម្ភារៈការិយាល័យនិងការបោះពុម្ព | 503,100,000.0 | 503,100,000.0 | 115,100,000.0 | 388,000,000.0 | 28,775,000.0 | 22.88% |
| | 6003 | | ស្បៀងអាហារនិងផលិតផលកសិកម្ម | 7,100,000.0 | 7,100,000.0 | 7,100,000.0 | 0.0 | 1,775,000.0 | 100.00% |
| | | 60031 | ស្បៀង | 7,100,000.0 | 7,100,000.0 | 7,100,000.0 | 0.0 | 1,775,000.0 | 100.00% |
| | 6005 | | សម្ភារៈតូចតាច សម្លៀកបំពាក់ និងសម្ភារៈបរិក្ខារ | 110,000,000.0 | 110,000,000.0 | 4,900,000.0 | 105,100,000.0 | 1,225,000.0 | 4.45% |
| | | 60051 | សម្ភារៈនិងបរិក្ខារបច្ចេកទេស | 82,000,000.0 | 82,000,000.0 | 1,200,000.0 | 80,800,000.0 | 300,000.0 | 1.46% |
| | | 60052 | សម្លៀកបំពាក់ | 27,600,000.0 | 27,600,000.0 | 3,300,000.0 | 24,300,000.0 | 825,000.0 | 11.96% |
| | | 60053 | សម្ភារៈប្រើប្រាស់ | 400,000.0 | 400,000.0 | 400,000.0 | 0.0 | 100,000.0 | 100.00% |
| 61 | | | សេវាកម្ម | 855,000,000.0 | 788,900,000.0 | 726,200,000.0 | 62,700,000.0 | 181,550,000.0 | 92.05% |
| | 6105 | | ការថែទាំនិងជួសជុល | 17,200,000.0 | 17,200,000.0 | 17,200,000.0 | 0.0 | 4,300,000.0 | 100.00% |
| | | 61057 | ការថែទាំនិងជួសជុលសម្ភារៈនិងឧបករណ៍បច្ចេកទេស | 17,200,000.0 | 17,200,000.0 | 17,200,000.0 | 0.0 | 4,300,000.0 | 100.00% |
| | 6110 | | ទំនាក់ទំនងសាធារណៈនិងផ្សព្វផ្សាយ | 57,000,000.0 | 57,000,000.0 | 4,300,000.0 | 52,700,000.0 | 1,075,000.0 | 7.54% |
| | | 61103 | ប្រជុំ សិក្ខាសាលា និងសន្និសីទ | 57,000,000.0 | 57,000,000.0 | 4,300,000.0 | 52,700,000.0 | 1,075,000.0 | 7.54% |
| | 6111 | | ចំណាយលើការជាវសារព័ត៌មាននិងឯកសារ | 500,000.0 | 500,000.0 | 500,000.0 | 0.0 | 125,000.0 | 100.00% |
| | | 61111 | ចំណាយលើការជាវសារព័ត៌មាន | 500,000.0 | 500,000.0 | 500,000.0 | 0.0 | 125,000.0 | 100.00% |
| | 6112 | | ចំណាយទូទាត់សោហ៊ុយក្នុងប្រទេស | 694,600,000.0 | 694,600,000.0 | 694,600,000.0 | 0.0 | 173,650,000.0 | 100.00% |
| | | 61121 | សោហ៊ុយដឹកជញ្ជូន | 88,800,000.0 | 88,800,000.0 | 88,800,000.0 | 0.0 | 22,200,000.0 | 100.00% |

| ជំពូក | គណនី | អនុគណនី | បរិយាយ | ច្បាប់ហិរញ្ញវត្ថុ ឆ្នាំ ២០១៧ | ឥណទាន ដែលជ្រើសរើស | ឥណទាន រដ្ឋលេខាធិការបានប្រគល់ | ឥណទាន ទូទាត់គ្រប់ | ឥណទានបង្គរជុំបង្គិល រដ្ឋលេខាធិការបានប្រគល់ | ភាគរយ |
|---|---|---|---|---|---|---|---|---|---|
| | | | | ១ | ២ | ៣ | ៤= ២-៣ | ៥= ៣/ ៤ជុំ | ៦= ៣/ ២ |
| | | 61122 | សោហ៊ុយបេសកកម្ម | 83,500,000.0 | 83,500,000.0 | 83,500,000.0 | 0.0 | 20,875,000.0 | 100.00% |
| | | 61123 | សោហ៊ុយស្នាក់នៅ | 522,300,000.0 | 522,300,000.0 | 522,300,000.0 | 0.0 | 130,575,000.0 | 100.00% |
| | 6113 | | ចំណាយទូទាត់សោហ៊ុយក្រៅប្រទេស | 66,100,000.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | 61131 | សោហ៊ុយដឹកជញ្ជូន | 31,100,000.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | 61132 | សោហ៊ុយបេសកកម្ម | 8,600,000.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | 61133 | សោហ៊ុយស្នាក់នៅ | 26,400,000.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | 6114 | | សោហ៊ុយប្រៃសណីយ៍និងទូរគមនាគមន៍ | 19,600,000.0 | 19,600,000.0 | 9,600,000.0 | 10,000,000.0 | 2,400,000.0 | 48.98% |
| | | 61142 | សោហ៊ុយទូរគមនាគមន៍ | 19,600,000.0 | 19,600,000.0 | 9,600,000.0 | 10,000,000.0 | 2,400,000.0 | 48.98% |

បានឃើញនិងពិនិត្យត្រឹមត្រូវ
រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ ១១ ឆ្នាំ២០១៧
ជ. អគ្គនាយក
អគ្គនាយកដ្ឋានរតនាគារជាតិ
អគ្គនាយករង
ម៉ិញ ប៊ុនសុវណ្ណអាទិត្យាសីលា

បានឃើញនិងពិនិត្យត្រឹមត្រូវ
រាជធានីភ្នំពេញ ថ្ងៃទី 01 ខែ 02 ឆ្នាំ២០១៧
ជ. អគ្គនាយក
អគ្គនាយកដ្ឋានថវិកា
គីម ចំរើន

បានឃើញនិងពិនិត្យត្រឹមត្រូវ
រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ មករា ឆ្នាំ២០១៧
អនុប្រធាននាយកដ្ឋានក្លាក់រួម
នាយកដ្ឋានគ្រប់គ្រងរដ្ឋបាលនិងបច្ចេកទេស
ពេជ សុខា

រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ មករា ឆ្នាំ២០១៧
រដ្ឋលេខាធិការប្រធាន
ស៊ូ សុដាន

បានឃើញ និងឯកភាព
រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ មករា ឆ្នាំ២០១៧
អគ្គនាយក
អគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ
កែវ ម៉េងវណ្ណន៍

បានឃើញ និងឯកភាព
រាជធានីភ្នំពេញ ថ្ងៃទី២៤ ខែ កុម្ភៈ ឆ្នាំ២០១៧
ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
អូន ព័ន្ធមុនីរ័ត្ន